**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹកនិងឧតុនិយម**

**មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់**

**ក្រុមលទ្ធកម្ម**

លេខ : ..០០៩..... ម.ធទឧ.ពស.កល

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃ ការងារស្តារប្រឡាយ ភូមិរបោះរាំង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ របស់មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់

មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុង ព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា÷ មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារស្តារប្រឡាយ ភូមិរបោះរាំង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ របស់មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ ។

មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន /សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់ នៅក្រុមលទ្ធកម្ម មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ ដែលមានអាសយដ្ឋាន នៅមន្ទីរធនធានទឹកនិងឧតុនិយម ខេត្តពោធិ៍សាត់ ចាប់ពីថ្ងៃទី.២៩.....ខែឧសភា...ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៧១ ៥៧៨ ៧៥ ៧៥ )។ ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៤.ខែមិថុនាឆ្នាំ២០១៨ វេលាម៉ោង ...៩:៣០.............។ ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង...៩:៣០.......................ថ្ងៃទី០៤.ខែមិថុនា.ឆ្នាំ ២០១៨ ។ ក្រុមហ៊ុន/ សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។ ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ.ព្រហស្បតិ៍.១០.កើត.ខែជេស្ឋ...ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ពោធិ៍សាត់, ថ្ងៃទី .២៤... ខែឧសភា. ឆ្នាំ ២០១៨

**ប្រធានមន្ទីរធនធានទឹក និងឧតុនិយម និងជា**

**ប្រធានក្រុមលទ្ធកម្ម**

**កែវ ជ័យ**

ចម្លងជូន

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ